# មហាបទុមជាតក




ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណវិកា បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ជាទដ្ឋា បរតោ ទោសំ** ដូច្នេះជាដើម ។

ក្នុងបឋមពោធិកាល ទេវតានិងមនុស្សជាច្រើនរកប្រមាណមិនបាន ជាសាវករបស់ព្រះទសពល បានចុះកាន់អរិយភូមិ ធ្វើឲ្យលាភសក្ការៈយ៉ាងច្រើនកើតឡើងដល់ព្រះសាស្តា ។ ពួកតិរ្ថិយទាំងឡាយប្រាកដដូចជាអំពិលអំពែកក្នុងពេលដែលព្រះអាទិត្យរះឡើង ជាអ្នកមានលាភសក្ការៈសាបសូន្យ ។ ពួកតិរ្ថិយឃោសនាតាមចន្លោះផ្លូវថា "មិនមែនតែសមណគោតមប៉ុណ្ណោះទេជាព្រះពុទ្ធ (អ្នកត្រាស់ដឹង) សូម្បីយើងទាំងឡាយក៏ជាព្រះពុទ្ធដែរ, មិនមែនតែទានដែលថ្វាយដល់សមណគោតមប៉ុណ្ណោះទេដែលមានផលច្រើន សូម្បី

ទានដែលថ្វាយដល់យើង ក៏មានផលច្រើនដែរ, អ្នកទាំងឡាយចូរឲ្យទានដល់យើងផង" សូម្បីពួកតិរ្ថិយឲ្យមនុស្សទាំងឡាយដឹងដូច្នេះហើយ ក៏នៅតែមិនបានលាភសក្ការៈ ទើបមកប្រជុំគ្នាក្នុងទីស្ងាត់ប្រឹក្សាគ្នាថា តើមានឧបាយណាហ្ន៎ ដែលនឹងញ៉ាំងទោសរបស់សមណគោតមឲ្យកើតឡើងដល់ពួកមនុស្ស ហើយធ្វើលាភសក្ការៈឲ្យវិនាស ។ គ្រានោះ ក្នុងក្រុងសាវត្ថី មានបរិព្វាជិកាម្នាក់ឈ្មោះ ចិញ្ចមាណវិកា ជាស្ត្រីមានរូបដ៏ល្អស្អាត ដល់ព្រមដោយសោភ័នភាព ហាក់បីដូចជាទេពអប្សរ, សរីរៈកាយរបស់នាងមានរស្មីផ្សាយចេញ ។

ពេលនោះ មានតិរ្ថិយម្នាក់មានសេចក្ដីគិតដ៏ក្លា ពោលថា យើងញ៉ាំងទោសរបស់សមណគោតមឲ្យកើតឡើងដោយអាស្រ័យនាងចិញ្ចមាណវិកា ហើយនឹងធ្វើលាភសក្ការៈឲ្យវិនាស ។ ពួកតិរ្ថិយទទួលថា ឧបាយនេះល្អ ។ ពេលនាងចិញ្ចមាណវិកាទៅកាន់អារាមតិរ្ថិយ ហើយថ្វាយបង្គំពួកតិរ្ថិយ, ពួកតិរ្ថិយមិនពោលចរចាជាមួយនឹងនាងឡើយ ។ នាងចិញ្ចាពោលអស់វារៈបីដងថា បពិត្រលោកម្ចាស់ ខ្ញុំសូមថ្វាយបង្គំ, ទោសរបស់ខ្ញុំមានដូចម្ដេច ? ហើយពោលទៀតថា បពិត្រលោកម្ចាស់ ទោសរបស់ខ្ញុំមានដូចម្ដេច, ហេតុអ្វី លោកម្ចាស់មិនពោលចរចាជាមួយនឹងខ្ញុំ ? ពួកតិរ្ថិយពោលថា នែប្អូនស្រី ពួកយើងត្រូវសមណគោតមបៀតបៀន ធ្វើឲ្យសាបសូន្យលាភសក្ការៈ នាងត្រាច់ទៅធ្វើមិនដឹងឬ ។ នាងចិញ្ចាពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងទេ តើខ្ញុំត្រូវធ្វើដូចម្ដេច ? ពួកតិរ្ថិយពោលថា នែប្អូនស្រី បើនាងប្រាថ្នាសេចក្ដីសុខដល់យើង, នាងចូរញ៉ាំងទោសឲ្យកើតឡើងដល់សមណគោតម ដោយអាស្រ័យខ្លួននាង ហើយធ្វើលាភសក្ការៈរបស់ទ្រង់ឲ្យវិនាស ។

នាងចិញ្ចាពោលថា "បពិត្រលោកម្ចាស់ រឿងនេះជាភារៈរបស់ខ្ញុំ សូមកុំគិតច្រើន" ថារួច នាងចៀសចេញទៅ, ដោយនាងជាអ្នកឈ្លាសក្នុងមាយាស្ត្រី តាំងពីថ្ងៃនោះមក វេលាដែលអ្នកក្រុងសាវត្ថីស្ដាប់ធម្មកថារួចចេញពីវត្តជេតពនវិញ នាងស្លៀកសំពត់ពណ៌ដូចមេភ្លៀង ដៃកាន់គ្រឿងក្រអូបនិងផ្កាកម្រងជាដើម ដើរទៅដោយមានមុខឆ្ពោះទៅរកវត្តជេតពន, កាលមនុស្សទាំងឡាយពោលថា នាងទៅណាក្នុងពេលនេះ ? នាងក៏ពោលថា

"ប្រយោជន៍អ្វីដោយទីដែលខ្ញុំទៅដល់ពួកលោក" រួចនាងទៅនៅក្នុងអារាមតិរ្ថិយដែលនៅជិតវត្តជេតពន, ពេលព្រឹក កាលពួកឧបាសកចេញពីនគរទៅដោយគិតថា "ពួកយើងនឹងថ្វាយបង្គំព្រះមានព្រះភាគ" នាងក៏ធ្វើដូចជាចេញពីវត្តជេតពនចូលទៅកាន់នគរ ។ កាលគេសួរថា នាងនៅក្នុងទីណា ? នាងពោលថា "ប្រយោជន៍អ្វីដោយទីនៅរបស់ខ្ញុំដល់ពួកលោក" កាលកន្លងទៅបានមួយខែកន្ទះ ពេលត្រូវគេសួរ នាងក៏ពោលថា ខ្ញុំនៅក្នុងគន្ធកុដិតែមួយជាមួយនឹងព្រះសមណគោតមក្នុងវត្តជេតពន ។

សេចក្តីសង្ស័យកើតឡើងដល់ពួកបុថុជ្ជនថា តើរឿងនេះពិតឬមិនពិត, ដោយកាលកន្លងទៅបានបីបួនខែ នាងយកសំពត់ចាស់មករុំពោះ ធ្វើឲ្យមានពណ៌សម្បុរដូចជាស្ត្រីមានគភ៌ ដណ្តប់សំពត់ក្រហមខាងលើ ញ៉ាំងមនុស្សល្ងង់ខ្លៅឲ្យសម្គាល់ថា "យើងមានគភ៌ដោយអាស្រ័យព្រះសមណគោតម" ដោយកាលកន្លងទៅបានប្រាំបីប្រាំបួនខែ នាងយកឈើមកចងនឹងពោះ ដណ្តប់សំពត់ក្រហមខាងលើ យកឈើមានសណ្ឋានដូចចង្កាគោមកវាយដៃជើងនិងខ្នង ធ្វើឲ្យមានភាពហើម ជាអ្នកមានឥន្ទ្រិយទន់ខ្សោយ, ក្នុងវេលាល្ងាច កាលព្រះតថាគតប្រថាប់លើធម្មាសនៈដែលប្រដាប់តាក់តែង ទ្រង់កំពុងសម្តែងធម៌, នាងទៅកាន់ធម្មសភា ឈរនៅខាងមុខព្រះតថាគត ហើយពោលថា "នែមហាសមណៈ លោកគិតតែសម្តែងធម៌ដល់មហាជន, សំឡេងរបស់លោកពីរោះណាស់, ធ្មេញរបស់លោកជិតស្និទ្ធល្អណាស់, ចំណែកខ្ញុំនេះមានគភ៌ដោយអាស្រ័យលោក គភ៌គ្រប់ខែហើយ, លោកមិនដឹងផ្ទះជាទីប្រសូតដល់ខ្ញុំទេ, លោកមិនឲ្យសប្បិ និងប្រេងជាដើមទេ, បើមិនធ្វើដោយខ្លួនឯង លោកក៏មិនពោលនឹងព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី ឧបាសិកាវិសាខា ឬឧបដ្ឋាកណាមួយថា អ្នកចូរធ្វើនូវកិច្ចដែលគប្បីធ្វើដល់នាងចិញ្ចមាណវិកានេះសោះ, លោកដឹងតែខាងអភិរម្យប៉ុណ្ណោះ, មិនដឹងនូវការរក្សាគភ៌" ដូច្នេះហើយ នាងក៏ជេរប្រទេចព្រះតថាគតក្នុងកណ្តាលបរិស័ទ ហាក់ដូចជាកាន់យកដុំអាចម៍ហើយព្យាយាមគប់ព្រះចន្ទ ។ ព្រះតថាគតបញ្ឈប់ធម្មកថា ទ្រង់មានអាការដូចជារាជសីហ៍ ត្រាស់ថា នែប្អូនស្រី ការពិតឬមិនពិតក្នុងរឿងដែលនាងពោល គឺមានតែតថាគត និងនាងប៉ុណ្ណោះ ទើបដឹង ។ នាងចិញ្ចា

ពោលថា ពិតមែនហើយសមណៈ រឿងនេះកើតឡើង មានតែលោកនិងខ្ញុំប៉ុណ្ណោះ ទើបដឹង ។

ខណៈនោះ ពិភពសក្កទេវរាជមានអាការក្តៅ ។ ស្តេចសក្កៈពិចារណាដឹងថា "នាងចិញ្ចមាណវិកាជេរព្រះតថាគតដោយរឿងមិនពិត" រួចទ្រង់គិតថា "យើងនឹងជម្រះរឿងនេះ" ដូច្នេះហើយ ទ្រង់ក៏យាងមកមួយអន្លើដោយទេវបុត្រ ៤ រូប ។ ទេវបុត្រទាំងនោះក្លែងភេទជាកូនកណ្តុរ ទៅកាត់ខ្សែដែលចងឈើដោយការកាត់តែម្តងប៉ុណ្ណោះ, ធ្វើឲ្យមានខ្យល់បក់សើយសំពត់ដណ្តប់ឡើង, ធ្វើឲ្យឈើធ្លាក់លើខ្នងជើងនាង, ចុងជើងទាំងពីរក៏បែក ។

មនុស្សទាំងឡាយក្រោកឡើង ពោលថា "នែស្រីកាឡកណ្ណី នាងឯងជេរប្រទេចព្រះសម្មាសម្ពុទ្ធ" ថារួចក៏ស្តោះទឹកមាត់ដាក់ក្បាល ម្នាក់ៗមានដៃកាន់ដុំដីនិងដំបងជាដើម ដេញនាងចិញ្ចាចេញពីវត្តជេតពន ។ កាលនាងចិញ្ចាចេញទៅកន្លងផុតចក្ខុរបស់ព្រះតថាគត មហាប្រឹថពីក៏បែក ធ្វើឲ្យមានចន្លោះ, សំណាញ់ភ្លើងតាំងឡើងពីឋានអវីចិនរក ។ នាងចិញ្ចាទៅកើតក្នុងអវីចិនរក ហាក់ដូចជាដណ្តប់សំពត់កម្ពលដែលត្រកូលឲ្យ ។ លាភសក្ការៈកាន់តែសាបសូន្យដល់ពួកអន្យតិត្ថិយ, ទៅចម្រើនឲ្យក្រៃលែងឡើងដល់ព្រះទសពល ។

ថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា ម្នាលអាវុសោ នាងចិញ្ចមាណវិកា ជេរប្រទេចព្រះសម្មាសម្ពុទ្ធដែលមានគុណជាឱឡារិក ដែលជាអគ្គទក្ខិណេយ្យបុគ្គលយ៉ាងនេះ ដោយរឿងមិនពិត ហើយក៏ដល់សេចក្តីវិនាសធំ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយរឿងអ្វី ? កាលពួកភិក្ខុទូលថា រឿងនេះ ទើបព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនកាលឥឡូវនេះទេ សូម្បីកាលមុន នាងចិញ្ចាក៏ជេរតថាគតដោយរឿងមិនពិត ហើយដល់សេចក្តីវិនាសធំដែរ រួចហើយទ្រង់នាំយកអតីតនិទានមកថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទៃព្រះអគ្គមហេសីរបស់ព្រះរាជានោះ, (ពេលលោកប្រសូតមកហើយ) ពពួកញាតិថ្វាយ ព្រះនាមថា **បទុមកុមារ** ព្រោះលោកមានមុខដូចផ្កាឈូករីក ។ លោកចម្រើនវ័យធំហើយ ទៅនគរតក្កសិលា សិក្សារៀនសូត្រ ហើយត្រឡប់មកវិញ ។ ពេលនោះមាតារបស់ព្រះអង្គធ្វើកាលកិរិយា ។ ព្រះរាជាតែងតាំងស្ត្រីដទៃជាអគ្គមហេសី និងប្រទានតំណែងឧបរាជដល់ព្រះពោធិសត្វ ។

សម័យខាងក្រោយមក ព្រះរាជាត្រាស់នឹងអគ្គមហេសីដើម្បីទៅរង្វាប់បច្ចន្តជនបទដែលបះបោរថា នែនាងដ៏ចម្រើន នាងចូរនៅទីនេះចុះ យើងនឹងទៅបង្ក្រាបបច្ចន្តជនបទដែលបះបោរ ។ ព្រះអគ្គមហេសីពោលថា ខ្ញុំម្ចាស់មិននៅទីនេះទេ សូម្បីខ្ញុំម្ចាស់នឹងទៅដែរ។ ព្រះរាជាសម្ដែងទោសក្នុងសមរភូមិហើយ ត្រាស់ថា "ដរាបណាយើងមិនទាន់មក នាងកុំអផ្សុកអី, បទុមកុមារជាអ្នកមិនប្រមាទក្នុងកិច្ចដែលគប្បីធ្វើដល់នាងយ៉ាងណា យើងនឹងត្រាស់បង្គាប់យ៉ាងនោះហើយនឹងទៅ" រួចព្រះអង្គធ្វើយ៉ាងនោះហើយ ទ្រង់យាងទៅ ធ្វើសត្រូវឲ្យរត់ខ្ចាត់ខ្ចាយអស់ ញុំាងជនបទឲ្យស្ងប់ កាលត្រឡប់មកវិញ ឲ្យរាជបុរសធ្វើបន្ទាយសម្រាកនៅខាងក្រៅព្រះនគរ ។ ព្រះពោធិសត្វដឹងថា ព្រះបិតាយាងត្រឡប់មកវិញ ក៏ឲ្យគេតាក់តែងព្រះនគរ និងបោសសម្អាតព្រះរាជវាំង ហើយទៅកាន់សំណាក់ព្រះមាតាចុងតែម្នាក់ឯង ។

ព្រះនាងឃើញរូបសម្បត្តិរបស់ព្រះពោធិសត្វហើយមានចិត្តប្រតិព័ទ្ធ ។ ព្រះពោធិសត្វថ្វាយបង្គំព្រះនាង រួចសួរថា បពិត្រព្រះមាតា ទូលបង្គំត្រូវធ្វើកិច្ចដូចម្ដេច ? ពេលនោះ ព្រះនាងពោលថា "អ្នកកុំហៅយើងថាមាតាឡើយ" ថារួចព្រះនាងក្រោកឡើងចាប់ដៃព្រះពោធិសត្វ និងពោលថា ចូរឡើងលើទីផ្ទំ ។ ព្រះពោធិសត្វពោលថា ព្រោះហេតុអ្វី ? ព្រះនាងពោលថា ព្រះរាជាមិនទាន់យាងមក ដរាបណា, យើងទាំងពីរនឹងត្រេកត្រអាលដោយសេចក្ដីត្រេកអរនៃកិលេសដរាបនោះ ។ ព្រះពោធិសត្វពោលថា បពិត្រព្រះមាតា លោកជា

មាតារបស់ខ្ញុំផង ជាអ្នកមានស្វាមីផង ឈ្មោះថាមាតុគ្រាមដែលមានស្វាមីហួងហែង ខ្ញុំមិនដែលទម្លាយឥន្ទ្រិយសម្លឹងមើលដោយអំណាចកិលេសទេ, ខ្ញុំនឹងធ្វើកម្មអាក្រក់បែបនេះជាមួយព្រះមាតា បានដូចម្ដេច ។ ព្រះនាងទេវីពោលយ៉ាងនោះពីរបីដង កាលព្រះពោធិសត្វមិនប្រាថ្នា ក៏សួរថា អ្នកមិនធ្វើតាមពាក្យយើងឬ ? ព្រះពោធិសត្វឆ្លើយថា ពិតមែនហើយ ទូលបង្គំមិនធ្វើតាមទេ ។ ព្រះនាងពោលថា បើយ៉ាងនោះ យើងនឹងប្រាប់ព្រះរាជាឲ្យកាត់ក្បាលអ្នកឯង ។ ព្រះមហាសត្វពោលថា ចូរព្រះនាងធ្វើតាមសេចក្ដីពេញចិត្តចុះ ថារួចក៏ធ្វើព្រះមាតាចុងឲ្យខ្មាសអៀន រួចចៀសចេញទៅ ។

ព្រះនាងទេវីភ័យខ្លាច និងគិតថា "បើបទុមកុមារប្រាប់ព្រះបិតារបស់គេបានមុន, ជីវិតរបស់យើងនឹងមិនមាន, យើងនឹងប្រាប់ព្រះរាជាឲ្យបានមុន" គិតរួចព្រះនាងមិនសោយកត្តស្លៀកសំពត់ដែលមានពោមសៅហ្មង ធ្វើសរីរៈឲ្យមានភាពគ្រាំគ្រា ឲ្យសញ្ញាដល់ស្រីបម្រើថា "កាលព្រះរាជាសួរថា ព្រះទេវីនៅឯណា ពួកនាងចូរនិយាយថា ព្រះនាងឈឺ" ដូច្នេះហើយព្រះនាងផ្ដុំធ្វើជាមានជំងឺ ។ ចំណែកព្រះរាជាធ្វើប្រទក្សិណនគរ រួចឡើងកាន់និវេសន៍ កាលមិនឃើញអគ្គមហេសី ក៏ត្រាស់សួរថា ព្រះទេវីនៅឯណា ? ទ្រង់បានស្ដាប់ថា ព្រះនាងឈឺ ទើបយាងចូលកាន់បន្ទប់ ត្រាស់សួរព្រះនាងថា នៃទេវី នាងមិនស្រួលខ្លួនដូចម្ដេច ?

ព្រះនាងធ្វើដូចជាមិនឮពាក្យរបស់ព្រះរាជា កាលព្រះរាជាសួរអស់ពីរបីដង ទើបពោលថា បពិត្រមហារាជ ព្រោះហេតុអ្វី បានព្រះអង្គត្រាស់យ៉ាងហ្នឹង, ព្រះអង្គចូរនៅស្ងៀមចុះ, ឈ្មោះថាស្ត្រីដែលមានស្វាមីហួងហែង មិនមែនជាខ្ញុំម្ចាស់ទេ ។ ព្រះរាជាត្រាស់ថា តើអ្នកណាបៀតបៀននាង ចូរប្រញាប់ប្រាប់យើងចុះ យើលនឹងកាត់ក្បាលវា ។ ព្រះនាងពោលថា បពិត្រមហារាជ ព្រះអង្គតែងតាំងអ្នកណា (ឲ្យជាអ្នករក្សានគរ) ហើយយាងទៅ ? ព្រះរាជាត្រាស់ថា គឺបទុមកុមារ ។ ព្រះនាងពោលថា បទុមកុមារនោះមកដំណាក់ខ្ញុំម្ចាស់ សូម្បីខ្ញុំម្ចាស់ពោលថា "នៃកូន អ្នកកុំធ្វើយ៉ាងនេះឡើយ យើងជាមាតារបស់អ្នក" តែគេពោលថា "បុគ្គលដទៃក្រៅពីយើង មិនមានអ្នកណាជាព្រះរាជាឡើយ យើងនឹងធ្វើនាងឲ្យក្នុងនិវេសន៍

ហើយអភិរម្យដោយអំណាចកិលេស" ថារួចចាប់សក់ខ្ញុំម្ចាស់ទាញទៅទាញមក ញ៉ាំងខ្ញុំម្ចាស់ដែលមិនធ្វើតាមពាក្យរបស់ខ្លួនឲ្យដួលចុះ វាយដំខ្ញុំម្ចាស់ ហើយក៏ទៅ ។

ព្រះរាជាមិនពិចារណា ខឹងក្រោធហាក់ដូចជាអាសិរពិស បញ្ជារាជបុរសថា នែ៎ព្រះស្តេង អ្នកទាំងឡាយចូរទៅ នាំគ្នាចាប់ចងបទុមកុមារនាំមក ។ ពួករាជបុរសទៅកាន់និវេសន៍ព្រះពោធិសត្វ ចាប់ចង វាយប្រហារ ចងស្ទាបសេកដ៏មាំ យកកម្រងផ្កាច្បាក្រហមពាក់នឹងកធ្វើឲ្យជាអ្នកទោសត្រូវប្រហារជីវិត នាំទៅ ។ ព្រះមហាសត្វដឹងថា "អំពើនេះជារបស់ព្រះទេវី" ទ្រង់ត្អូញត្អែរ យាងទៅដោយពោលថា នែអ្នកទាំងឡាយ យើងមិនបានធ្វើទោសដល់ព្រះរាជា យើងមិនមានកំហុសទេ ។ អ្នកនគរទាំងអស់ផ្អើលឆោឡោថា បានឮថា ព្រះរាជាជឿកាន់យកតាមពាក្យមាតុគ្រាម (ស្ត្រី) ឲ្យគេសម្លាប់មហាបទុមកុមារ ដូច្នេះហើយមកប្រជុំគ្នា ក្រាបចុះទៀបបាទមូលរបស់ព្រះរាជកុមារ យំស្រែកដោយសំឡេងខ្លាំងថា បពិត្រព្រះអង្គម្ចាស់អំពើនេះមិនមែនជារបស់ព្រះអង្គទេ ។

ពេលនោះ ពួករាជបុរសនាំទៅថ្វាយព្រះរាជា ។ ព្រះរាជាគ្រាន់តែឃើញប៉ុណ្ណោះ ទ្រង់មិនអាចអត់សង្កត់ចិត្តបាន ត្រាស់ថា កុមារនេះមិនមែនជាព្រះរាជាទេ តែធ្វើអាការជាព្រះរាជា, ជាបុត្ររបស់យើងតែទៅប្រទូស្តអគ្គមហេសីរបស់យើង, អ្នកទាំងឡាយចូរនាំទៅចាប់ទម្លាក់ក្នុងជ្រោះទម្លាក់ចោរ ធ្វើឲ្យដល់សេចក្តីវិនាសចុះ ។ ព្រះមហាសត្វអង្វរព្រះបិតាថាបពិត្របិតា ទោសបែបនោះមិនមានដល់ខ្ញុំទេ, ព្រះអង្គកុំជឿពាក្យមាតុគ្រាមហើយធ្វើខ្ញុំឲ្យវិនាសឡើយ ។ ព្រះរាជាមិនជឿពាក្យព្រះពោធិសត្វ ។

លំដាប់នោះ ស្ត្រីក្នុងព្រះរាជវាំងទាំង ១៦០០០ យំស្រែកខ្លាំងៗថា បពិត្រមហាបទុមកុមារ អំពើដែលព្រះអង្គទទួលនេះ មិនសមគួរទេ ។ សូម្បីពួកខត្តិយមហាសាលជាដើមទាំងអស់ សូម្បីពួកអាមាត្យ និងជនជាបរិវារក្តី ក៏ពោលថា បពិត្រព្រះសម្មតិទេព ព្រះកុមារដល់ព្រមដោយគុណគឺសីលាចារវត្ត ជាអ្នករក្សាវង្សត្រកូល ជារជ្ជទាយាទ ព្រះអង្គកុំជឿតាម

*ពាក្យមាតុគ្រាម មិនពិចារណា ហើយធ្វើបទុមកុមារឲ្យវិនាស ធម្មតាព្រះរាជាមិនគប្បីធ្វើដោយមិនពិចារណាឡើយ ដូច្នេះហើយ នាំគ្នាពោល ៧ គាថាថា*

ជានទ្ធា បរតោ ទោសំ, អណុំ ថូលានិ សព្ពសោ;
ឥស្សរោ បណយេ ទណ្ឌំ, សាមំ អប្បដិវេក្ខិយ។

*ព្រះរាជាជាឥស្សរៈ បើមិនទាន់ឃើញទោសតូចធំ ដោយសព្វគ្រប់ អំពីសម្នាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណាឲ្យឃើញច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ ។*

យោ ច អប្បដិវេក្ខិត្វា, ទណ្ឌំ កុព្ពតិ ខត្តិយោ;
សកណ្ដកំ សោ គិលតិ, ជច្ចន្ធោវ សមក្ខិកំ។

*បើក្សត្រិយ៍ណា មិនទាន់ពិចារណា ហើយធ្វើអាជ្ញា ក្សត្រិយ៍នោះ ឈ្មោះថា លេបភោជន ប្រកបដោយបន្លា ប្រកបដោយរុយ ដូចជាមនុស្សខ្វាក់ ។*

អទណ្ឌិយំ ទណ្ឌយតិ, ទណ្ឌិយញ្ច អទណ្ឌិយំ;
អន្ធោវ វិសមំ មគ្គំ, ន ជានាតិ សមាសមំ។

*ព្រះរាជាណា ដាក់អាជ្ញាដល់បុគ្គល ដែលមិនគួរដាក់អាជ្ញា មិនដាក់អាជ្ញាដល់បុគ្គលដែលគួរដាក់អាជ្ញា ព្រះរាជានោះ ឈ្មោះថា មិនដឹងការស្មើ និងមិនស្មើ ដូចជាមនុស្សខ្វាក់ ដើរតាមផ្លូវមិនរាបស្មើ ។*

យោ ច ឯតានិ ឋានានិ, អណុំ ថូលានិ សព្ពសោ;
សុទិដ្ឋមនុសាសេយ្យ, ស វេ វោហរិតុ មរហតិ។

*ព្រះរាជាណា ឃើញនូវហេតុទាំងឡាយតូច និងធំនុំះ ដោយសព្វគ្រប់ ជាហេតុ ដែលឃើញត្រឹមត្រូវហើយ សឹមប្រៀនប្រដៅ ព្រះរាជានោះទើបគួរហៅថា ព្រះរាជាបាន ។*

នេកច្ឆន្ទមុទុនា សក្កា, ឯកច្ឆន្ទតិខិណេន វា;
អត្តំ មហន្តេ ឋបេតុំ, តស្មា ឧភយមាចរេ។

*ព្រះរាជា ដែលមានព្រះទ័យទន់ពេក មានព្រះទ័យរឹងពេក ក៏មិនអាចតាំងខ្លួន ក្នុងភាពជាធំបានទេ ហេតុនោះ ព្រះរាជាគួរប្រព្រឹត្តនូវហេតុទាំងពីរ ។*

បរិភូតោ មុទុ ហោតិ, អតិតិក្ខោ ច វេរវា;
ឯតញ្ច ឧភយំ ញត្វា, អនុមជ្ឈំ សមាចរេ។

*(ព្រោះ) ព្រះរាជា ដែលមានព្រះទ័យទន់ ត្រូវពួករាស្ត្រមើលងាយ ឯព្រះរាជាមានព្រះទ័យរឹងពេក រមែងមានពៀរ(ការចងពៀរ) ព្រះរាជាជ្រាបហេតុទាំងពីរនោះហើយ ត្រូវប្រព្រឹត្តជាកណ្តាល ។*

ពហុម្បិ រត្តោ ភាសេយ្យ, ទុដ្ឋោបិ ពហុ ភាសតិ;
ន ឥត្ថិការណា រាជ, បុត្តំ ឃាតេតុមរហសិ។

*បុគ្គលត្រេកអរហើយ និយាយច្រើនក៏មាន បុគ្គលខឹងហើយ និយាយច្រើក៏មាន បពិត្រមហារាជ ព្រះអង្គមិនគួរសម្លាប់ព្រះរាជបុត្រ ព្រោះហេតុតែស្ត្រីទេ ។*

*សូម្បីពួកអាមាត្យពោលអាងហេតុផលផ្សេងៗយ៉ាងនេះហើយ ក៏មិនអាចនឹងឲ្យព្រះរាជាជឿតាមពាក្យរបស់ខ្លួនដែរ ។ សូម្បីព្រះពោធិសត្វអង្វរ ក៏មិនអាចឲ្យព្រះរាជាជឿពាក្យខ្លួនដែរ ។ ចំណែកព្រះរាជាល្ងង់ខ្លៅ ត្រាស់ថា អ្នកទាំងឡាយចូរនាំកុមារនេះទៅទម្លាក់ក្នុងជ្រោះទម្លាក់ចោរ ដូច្នេះកាលនឹងបញ្ជាពួករាជបុរស ទើបត្រាស់គាថាទី ៨ ថា*

សព្ពោវ លោកោ ឯកតោ, ឥត្ថី ច អយមេកិកា;
តេនាហំ បដិបជ្ជិស្សំ, គច្ឆថ បក្ខិបថេវ តំ។

*មនុស្សលោកទាំងអស់ (ជាបក្ខពួកខាងកុមារ) ឯស្ត្រីនោះតែម្នាក់ឯងទេ ព្រោះហេតុនោះ យើងនឹងប្រតិបត្តិ (តាមពាក្យនាងនេះវិញ) អ្នកឯងចូរទៅទម្លាក់វា (ក្នុងជ្រោះភ្នំទៅ) ។*

*កាលស្រីស្នំទាំង ១៦០០០ ពោលយ៉ាងនេះហើយ សូម្បីស្ត្រីតែម្នាក់ក៏មិនអាចតាំងនៅដោយសភាពរបស់ខ្លួនបានឡើយ អ្នកនគរទាំងអស់ផ្គងដៃ កន្ទក់កន្ទិញ មានសក់រោយរាយយំត្អូញត្អែររៀបរាប់ដោយប្រការផ្សេងៗ ។ ព្រះរាជាត្រាស់ថា "អ្នកទាំងឡាយហ៊ានការពារការទម្លាក់ក្នុងជ្រោះដល់កុមារនេះឬ" ជារួចទ្រង់យាងទៅជាមួយនឹងបរិវាររបស់ខ្លួន កាលមហាជនកំពុងស្រែកយំ ទ្រង់ឲ្យគេចាប់បទុមកុមារធ្វើឲ្យមានក្បាលសំយុងចុះ មានជើងឡើងលើ បោះទម្លាក់ទៅក្នុងជ្រោះ ។*

*លំដាប់នោះ ដោយអានុភាពមេត្តារបស់ព្រះពោធិសត្វ ទេវតាដែលអាស្រ័យនៅនឹងភ្នំពោលលួងលោមព្រះអង្គថា បពិត្រមហាបទុម ព្រះអង្គកុំភ័យឡើយ ដូច្នេះហើយក៏យកដៃទាំងពីរចាប់ព្រះពោធិសត្វមកផ្អឹបជាប់នៅនឹងទ្រូង, សម្ផស្សជាទិព្វផ្សាយទៅ លោកអណ្តែតធ្លាក់ចុះហើយ ទេវតាយកលោកទៅដាក់លើផ្ទៃក្អែនាគរាជដែលបិតនៅជើងភ្នំ ។ នាគរាជនាំព្រះពោធិសត្វទៅកាន់ពិភពនាគ ហើយបែកចែកយសសម្បត្តិរបស់ខ្លួនពាក់កណ្តាលថ្វាយ ។ ព្រះមហាសត្វនៅក្នុងទីនោះអស់ ១ ឆ្នាំ ហើយពោលថា ខ្ញុំនឹងទៅស្រុកមនុស្ស ។ នាគរាជសួរថា ព្រះអង្គចង់ទៅទីណា ? ព្រះពោធិសត្វឆ្លើយថា ខ្ញុំនឹងទៅព្រៃហិមពាន្តហើយបួស ។ នាគរាជពោលថា ល្អ រួចនាំព្រះពោធិសត្វទៅដាក់លើផ្លូវមនុស្ស ហើយថ្វាយបរិក្ខាររបស់បព្វជិត និងទៅកាន់លំនៅខ្លួនវិញ ។ ចំណែកព្រះមហាសត្វចូលទៅកាន់ព្រៃហិមពាន្តបួសជាឥសី ធ្វើឈានអភិញ្ញាឲ្យកើតឡើង ជាអ្នកមានមើមឈើផ្លែឈើក្នុងព្រៃជាអាហារហើយរស់នៅក្នុងទីនោះឯង ។*

*លំដាប់នោះ មានព្រានព្រៃម្នាក់ជាអ្នករស់នៅក្នុងក្រុងពារាណសី បានទៅដល់ទីនោះចំណាំព្រះមហាសត្វបាន ហើយពោលថា បពិត្រទេវៈ លោកជាមហាបទុមកុមារឬ ? ព្រះពោធិសត្វពោលថា ពិតមែនហើយ សម្លាញ់ ។ ព្រានព្រៃថ្វាយបង្គំព្រះពោធិសត្វ និងនៅទី*

*នោះអស់ពីរបីថ្ងៃ ហើយទៅកាន់នគរពារាណសី ប្រាប់ដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព បុត្ររបស់ព្រះអង្គបួសជាឥសី នៅក្នុងបណ្ណសាលា ក្នុងព្រៃហិមពាន្ត, ទូលព្រះបង្គំនៅក្នុងសំណាក់ព្រះកុមារ ហើយទើបតែមក ។ ព្រះរាជាសួរថា អ្នកបានឃើញគេពិតប្រាកដឬ ? ព្រានព្រៃឆ្លើយថា ពិតមែនហើយ ព្រះសម្មតិទេព ។*

*ព្រះរាជាមានពួកសេនាយោធាដ៏ធំជាបរិវារ យាងទៅទីនោះ ឲ្យគេធ្វើបន្ទាយនៅខាងចុងព្រៃ ទ្រង់មានពួកអាមាត្យចោមរោម យាងទៅកាន់បណ្ណសាលា ឃើញព្រះមហាសត្វកំពុងអង្គុយនៅជិតទ្វារបណ្ណសាលា ទ្រង់ថ្វាយបង្គំព្រះពោធិសត្វ ហើយប្រថាប់គង់ទីកន្លែងមួយ ។ សូម្បីពួកអាមាត្យថ្វាយបង្គំ និងធ្វើបដិសណ្ឋារៈ ហើយអង្គុយ ។ ចំណែកព្រះពោធិសត្វឆ្លើយតប និង ធ្វើបដិសណ្ឋារៈដល់ព្រះរាជា ។ ពេលនោះ ព្រះរាជាត្រាស់នឹងព្រះមហាសត្វថា នែបុត្រ យើងបានឲ្យគេទម្លាក់អ្នកក្នុងជ្រោះដ៏ជ្រៅ អ្នកមានជីវិតបានដូចម្ដេចដូច្នេះហើយកាលនឹងសួរ ទើបត្រាស់គាថាទី ៩ ថា*

**អនេកតាលេ នរកេ, គម្ភីរេ ច សុទុត្តរេ;**
**បាតិតោ គិរិទុគ្គស្មិំ, កេន ត្វំ តត្ថ នាមរិ។**

***យើងជាបិតា បានឲ្យគេយកកូនឯង ទៅបោះក្នុងជ្រោះភ្នំដ៏ជ្រៅ ច្រើនដួរត្នោត មិនងាយឡើងមករួចទេ ហេតុអ្វីបានជាកូនឯង មិនស្លាប់ក្នុងជ្រោះនោះ ។***

*បន្ទាប់ពីនេះទៅ មាន ៥ គាថា គឺ ៣ គាថារបស់ព្រះពោធិសត្វ, ២ គាថារបស់ព្រះរាជា ដោយការពោលម្ដងម្នាក់ថា*

(មហាបទុមតាបសពោលថា)

**នាគោ ជាតផណោ តត្ថ, ថាមវា គិរិសានុជោ;**
**បច្ចគ្គហិ មំ ភោគេហិ, តេនាហំ តត្ថ នាមរិំ។**

*ក្នុងវេលានោះ នាគរាជមានកម្លាំងដ៏ខ្លាំងពូកែ អាស្រ័យនៅនឹងភ្នំ បានទទួលទ្រអាត្មាភាព ដោយភ្លេនទាំងឡាយ ហេតុនោះ បានជាអាត្មា មិនស្លាប់ក្នុងជ្រោះនោះ ។*

(ព្រះរាជាត្រាស់ថា)

ឯហិ តំ បដិនេស្សាមិ, រាជបុត្ត សកំ ឃរំ;
រជ្ជំ ការេហិ ភទ្ទន្តេ, កឹ អរញ្ញេ ករិស្សសិ។

*ម្នាលរាជបុត្រ សូមលោកនិមន្តមក យើងនឹងនាំលោកទៅកាន់ផ្ទះរបស់ខ្លួនវិញ ម្នាលលោកដ៏ចម្រើន សូមលោកគ្រប់គ្រងរាជសម្បត្តិចុះ លោកនៅធ្វើអ្វីក្នុងព្រៃ ។*

(មហាបទុមតាបសពោលថា)

យថា គិលិត្វា ពឡិសំ, ឧទ្ធរេយ្យ សលោហិតំ;
ឧទ្ធរិត្វា សុខី អស្ស, ឯវំ បស្សាមិ អត្តនំ។

*បុគ្គលលេបផ្លែសន្ទូច ហើយទាញចេញមក លុះទាញចេញមក ព្រមទាំងឈាម គប្បីជាសុខយ៉ាងណា អាត្មាភាពឃើញច្បាស់ ដោយខ្លួនឯង ក៏យ៉ាងនោះដែរ ។*

(ព្រះរាជាត្រាស់ថា)

កឹ នុ ត្វំ ពឡិសំ ព្រូសិ, កឹ ត្វំ ព្រូសិ សលោហិតំ;
កឹ នុ ត្វំ ឧព្ភតំ ព្រូសិ, តំ មេ អក្ខាហិ បុច្ឆិតោ។

*លោកពោលថា អ្វីជាផ្លែសន្ទូច លោកពោលថា អ្វីជាឈាម លោកពោលថា អ្វីទាញចេញមក កាលបើយើងសួរហើយ លោកចូរប្រាប់រឿងនោះ ។*

(មហាបទុមតាបសពោលថា)

**កាមាហំ ពឡិសំ ព្រូមិ, ហត្ថិអស្សំ សលោហិតំ;**
**ចត្តាហំ ឧឡ្ហតំ ព្រូមិ, ឃរា ជាជាហិ ខត្តិយ។**

*អាត្មាភាព ពោលនូវកាមថា ជាផ្លែសន្ទូច ពោលនូវដំរីនិងសេះថា ជាឈាម ពោលនូវការលះចោលថា ជាគ្រឿងទាញចេញមក បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។*

*ពាក្យថា **នាគរាជមានកម្លាំងដ៏ខ្លាំងពូកែ អាស្រ័យនៅនឹងភ្នំ បានទទួលទ្រអាត្មា** សេចក្តីថា ព្រះមហាសត្វប្រាប់រឿងរ៉ាវទាំងអស់ដល់ព្រះរាជាថា កាលអាត្មាធ្លាក់ចុះពីភ្នំ មានទេវតាមកទទួលអាត្មា លួងលោមអាត្មាដោយសម្ផស្សទិព្វ ហើយនាំទៅ (ដាក់លើភ្នែននាគ), នាគរាជនាំអាត្មាទៅកាន់ពិភពនាគ ឲ្យយសដ៏ធំដល់អាត្មា, កាលអាត្មាពោលថា អ្នកចូរនាំអាត្មាទៅកាន់ផ្លូវមនុស្ស គេក៏នាំអាត្មាមកកាន់ផ្លូវមនុស្ស ។ អាត្មាមកបួសកក្នុងទីនេះ ព្រោះហេតុនោះបានជាអាត្មាមិនស្លាប់ក្នុងជ្រោះនោះ ដោយអានុភាពរបស់ទេវតានិងនាគរាជ ។*

*ព្រះមហាសត្វឲ្យឱវាទព្រះបិតាថា បពិត្រមហារាជ អាត្មាភាពមិនត្រូវការរាជសម្បត្តិទេ ចំណែកព្រះអង្គចូរកុំធ្វើទសរាជធម៌ឲ្យកម្រើក ត្រូវលះបង់អគតិ ចូរសោយរាជ្យប្រកបដោយធម៌ ។ ព្រះរាជានោះយំ ត្អូញត្អែរ យាងទៅកាន់នគរ ហើយសួរពួកអាមាត្យតាមផ្លូវថា យើងដល់នូវវិយោគទុក្ខដោយបុត្រដែលដល់ព្រមដោយគុណគឺអាចារៈ មានសភាពបែបនេះ ដោយអាស្រ័យអ្នកណា ? ពួកអាមាត្យពោលថា បពិត្រព្រះសម្មតិទេព ដោយអាស្រ័យអគ្គមហេសីរបស់ព្រះអង្គ ។ ព្រះរាជាបញ្ជាឲ្យរាជបុរសទៅចាប់អគ្គមហេសីនោះ ធ្វើឲ្យមានជើងឡើងលើ បោះទម្លាក់ក្នុងជ្រោះទម្លាក់ចោរ រួចព្រះអង្គចូលទៅកាន់នគរ ទ្រង់សោយរាជ្យប្រកបដោយធម៌ ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីកាលមុន នាងចិញ្ចានោះដេរតថាគត ហើយដល់សេចក្តីវិនាសធំដែរ ។*

**ចិញ្ចមាណវិកា មាតា, ទេវទត្តោ ច មេ បិតា;**

អានន្ទោ បណ្ឌិតោ ជាតោ, សារិបុត្តោ ច ទេវតា;
រាជបុត្តោ អហំ អាសឹ, ឯវំ ធារេថ ជាតកំ។

មាតាចុងនៃតថាគត គឺនាងចិញ្ចមាណវិកា, បិតាតថាគត គឺទេវទត្ត, នាគរាជ គឺអានន្ទ ជាអ្នកប្រាជ្ញ, ទេវតា គឺសារីបុត្រ, រាជបុត្រ ក្នុងកាលនោះ គឺតថាគត, អ្នកទាំងឡាយ ចូរចាំទុក នូវជាតក ដោយប្រការយ៉ាងនេះចុះ ។

*ព្រះសម្មាសម្ពុទ្ធប្រជុំជាតកដោយគាថាចុងក្រោយនេះឯង ។*

*មហាបទុមជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសកនិបាត បិដកលេខ ៥៩ ទំព័រ ២៦០)*

*ថ្ងៃច័ន្ទ ៣ កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ប.ស. ១៣៨១ ម.ស. ១៩៤១ ព.ស. ២៥៦២*

*ត្រូវនឹងថ្ងៃទី ៦ ខែឧសភា គ.ស. ២០១៩*

*ដោយសជវថ*